# ទិចារណកថា

ដោយលោក ដេវីឌ ចាន់ដល័រ

ខ្ញុំសូមថ្លែងអំណរគុណ សហការីរបស់ខ្ញុំ គឺលោក មីស្ហែល ឬទ្ធីអង់តែល្ម ដែលបានអញ្ជើញខ្ញុំ អោយចូលរួមសរសេរសេចក្តីឧទ្ទេលនាមយ៉ាងសង្ខេបសំរាប់ព្រឹត្តិប័ត្រនៃមជ្ឈមណ្ឌលខេមរសិក្សា ។ ខ្ញុំមានសេចក្តីរំភើបរីករាយក្រៃលែង ដែលបានចូលរួមជាមួយមជ្ឈមណ្ឌលខេមរសិក្សាក្នុងឋានៈជាទីប្រឹក្សាជាន់ខ្ពស់ ។

ដូចអ្នកទាំងអស់គ្នាបានដឹងហើយថា ខ្ញុំបានភ្ជាប់ខ្លួនជាមួយស្រុកខ្មែរចាប់តាំងពីឆ្នាំ ១៩៥៩ ពេលដែលខ្ញុំបានចាប់ផ្តើមរៀនភាសាជាមន្ត្រីសេវាកម្មបរទេសរបស់សហរដ្ឋអាមេរិច ។ ពេលខ្ញុំសុំលាឈប់ពីសេវាកម្មបរទេសនេះក្នុងឆ្នាំ ១៩៦៦ ខ្ញុំបានសំរេចចិត្តចាប់យកការសិក្សាជាន់ខ្ពស់ ដែលនិក្ខេបបទរបស់ខ្ញុំ ទាក់ទងនឹងប្រវត្តិសាស្ត្រនយោបាយកម្ពុជា នៅដើមសតវត្សទី១៩ មុនការមកដល់របស់បារាំង ។ ខ្ញុំបានបង្រៀនប្រវត្តិសាស្ត្រអាស៊ីអគ្នេយ៍ នៅឯសាកលវិទ្យាល័យ ម៉ូនាស្ហ (MONASH) ក្នុងប្រទេសអូស្ត្រាលី អស់រយៈកាល ២៥ឆ្នាំ ។ ប្រពន្ធរបស់ខ្ញុំ និងខ្ញុំ បានត្រឡប់ទៅរស់នៅសហរដ្ឋអាមេរិចវិញនៅដើមឆ្នាំ ១៩៩៨ ។ ចាប់តាំងពីឆ្នាំ ១៩៦០ ខ្ញុំបានមកលេងប្រទេសកម្ពុជា ១៤ដង សំរាប់ការពិគ្រោះយោបល់ និង ដើម្បីធ្វើការស្រាវជ្រាវផ្ទាល់ខ្លួនរបស់ខ្ញុំ ។ ក្នុងឆ្នាំ ១៩៩៩ ខ្ញុំបានតាមដានប្រវត្តិតំបូងនៃមជ្ឈមណ្ឌលខេមរសិក្សាដោយក្តីចាប់អារម្មណ៍ជាខ្លាំង ហើយបានចូលរួមជាផ្លូវការក្នុងកម្មវិធីរបស់មជ្ឈមណ្ឌល កាលខ្ញុំកំពុង បង្រៀននៅឯសាកលវិទ្យាល័យ ខោនេល (CORNELL) នៅដើមឆ្នាំនេះ ។ ខ្ញុំមានគំរោងធ្វើការក្នុងឋានៈជាអ្នកជំនួយការជាន់ខ្ពស់ អោយមជ្ឈមណ្ឌលដោយមានជំនាញខាងរៀបចំកម្មវិធីសិក្សារបស់ខ្លួនរហូតដល់ឆ្នាំ ២០០៣ ។ បន្ទាប់មកទៀត ខ្ញុំពិតជានឹងនៅតែបន្តការចាប់អារម្មណ៍ និងគាំទ្រយ៉ាងសកម្មចំពោះមជ្ឈមណ្ឌល ខេមរសិក្សា ។

ដោយធ្វើការជាមួយលោក ហ្វីលីព្ព ប៊ុកាំ និង សហការីរបស់គាត់នៅឯមជ្ឈមណ្ឌលជាមួយក្រុមប្រឹក្សាផ្តល់យោបល់ នៃមជ្ឈមណ្ឌលខេមរសិក្សា ដែលមានវិជ្ជាករពីបណ្តាប្រទេសមួយចំនួន រួមមានប្រទេសកម្ពុជាផងដែរ ហើយនិងជាមួយក្រុមប្រឹក្សានៃមជ្ឈមណ្ឌល ។ ខ្ញុំសង្ឃឹមថានឹងជួយមជ្ឈមណ្ឌលក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីពង្រីកនូវការយកចិត្តទុកដាក់ និងបង្កើនថាមពលដល់វិជ្ជាករទូទាំងពិភពលោក ក្នុងវិស័យខេមរសិក្សា ។ តាមរយៈការធ្វើសិក្ខាសាលា សន្និសីទ កម្មវិធីសិក្សា ព្រឹត្តិប័ត្រ ។ល។ មជ្ឈមណ្ឌលខេមរសិក្សាសង្ឃឹមថា នឹងដើរតួយ៉ាងរស់រវើកប្រកបដោយផ្លែផ្កា ដោយធ្វើជាការិយាល័យកណ្តាល សំរាប់ផ្លាស់ប្តូរយោបល់ និងផ្សព្វផ្សាយសំរាប់គំនិតផ្តួចផ្តើម ខាងផ្នែកការសិក្សាជាន់ខ្ពស់ ហើយជាពិសេសដោយជំរុញវិជ្ជាករខ្មែរដែលមានវ័យក្មេង អោយបន្តការសិក្សាក្រោយឧត្តមសិក្សាខាងផ្នែកខេមរសិក្សា ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅក្រៅប្រទេស ។

ទោះបីមជ្ឈមណ្ឌលខេមរសិក្សា ស្វាគមន៍នូវការគាំទ្រ និងការចូលរួមពីសំណាក់វិជ្ជាករបរទេស ក៏វាមានគំរោងផ្តល់ប្រាក់រង្វាន់ដល់តែបរទេសទាំងឡាយណា ដែលទទួលអត្ថប្រយោជន៍នៃការសិក្សាពីភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការដ៏ទូលំទូលាយជាមួយវិទ្យាស្ថាន និងវិជ្ជាករកម្ពុជាតែប៉ុណ្ណោះ ។ វិទ្យាស្ថាននិងវិជ្ជាករកម្ពុជា នឹងទទួលបានអត្ថប្រយោជន៍ពីភាពជាដៃគូនេះមកវិញ ។ មជ្ឈមណ្ឌលខេមរសិក្សា នឹងស្វែងរកប្រាក់ឧបត្ថម្ភផងដែរដល់វិជ្ជាករកម្ពុជា វ័យក្មេង ដោយរៀបចំសំរាប់ការសិក្សាក្រោយឧត្តមសិក្សានៅបរទេស និង ក្នុងប្រទេសកម្ពុជា ។

ខ្ញុំសង្ឃឹមថា បញ្ហាជាអទិភាពនៃមជ្ឈមណ្ឌលខេមរសិក្សា ក្នុងរយៈពេលពីរ ឬ បីឆ្នាំនេះ នឹងដាក់អោយអង្គសិក្ខាសាលា ដែលរៀបចំដោយមជ្ឈមណ្ឌលនៅខែ មករា ឆ្នាំ ២០០១ ក្នុងខេត្តសៀមរាប ។ ខ្ញុំសង្ឃឹមថា របៀបវារៈនៃការស្រាវជ្រាវ និង យុទ្ធសាស្ត្រជាទូទៅមួយសំរាប់ពីរ ឬ បីឆ្នាំ បន្ទាប់នឹងត្រូវគេសំរេចនៅពេលនោះ ។ ក្នុងចន្លោះពេលនេះដែរ សហការីរបស់ខ្ញុំ និងខ្ញុំស្វាគមន៍នូវគំនិតរបស់លោកអ្នកតាមរយៈសំបុត្រ ឬសារអេឡិត្រូនិច ។ អ្នកទាំងឡាយណាដែលមានបំណងចូលរួមក្នុងអង្គសិក្ខាសាលានេះ នឹងមានឱកាស ដើម្បីបញ្ចេញនូវទស្សនៈរបស់ខ្លួន និងចូលរួមចំណែកជាមួយអ្នកដទៃទៀត ដែលចាប់អារម្មណ៍ក្នុងការបង្កើន និង ធ្វើអោយស៊ីជំរៅដល់ការសិក្សា វប្បធម៌ សង្គម និងប្រវត្តិសាស្ត្រកម្ពុជា ។ អង្គសិក្ខាសាលា នឹងពិភាក្សាយ៉ាងល្អិតល្អន់ នៅទំព័រណាមួយផ្សេងទៀតក្នុងព្រឹត្តិប័ត្រនេះ ហើយខ្ញុំសង្ឃឹមថានឹងជួបអ្នកនៅទីនេះ។

ជាទីបញ្ចប់ ខ្ញុំសូមសំដែង នូវសេចក្តីរំភើបរីករាយ ដែលបានបំពេញតួនាទីជាទីប្រឹក្សាជាន់ខ្ពស់ នៃមជ្ឈមណ្ឌល ខេមរសិក្សា ។ ខ្ញុំសប្បាយរីករាយក្រៃលែង ដែលមកដល់គោលដៅមួយក្នុងមុខវិជ្ជាជីវៈរបស់ខ្ញុំ ខណៈដែលខ្ញុំអាចលះបង់ នូវពេលវេលាដ៏មានតំលៃជាច្រើន ក្នុងការព្យាយាមនាំមកនូវគំនិតទាំងឡាយ ដែលខ្ញុំបានរៀបរាប់ ដើម្បីទុកជាប្រយោជន៍ ហើយដើម្បីធ្វើជាការមួយវិជ្ជាករខ្មែរ និងបរទេស ដោយចូលរួមសហការជាមួយមជ្ឈមណ្ឌល ។ ខ្ញុំសង្ឃឹមថានឹងចំណាយពេល បីឬបួនខែ ក្នុងមួយឆ្នាំនៅមជ្ឈមណ្ឌល ហើយក៏សង្ឃឹមយ៉ាងមុតមាំថា នឹងមកអោយយូរជាងនេះ ដើម្បីធ្វើការ ជាមួយអ្នកទាំងអស់គ្នា បន្ទាប់ពី៤០ឆ្នាំ នៃការសិក្សាពីកម្ពុជា ដែលភាគច្រើន សិក្សាពីចម្ងាយ ។